C51

C51

Seed purification



# ការសំរិតសំរាំងពូជស្រូវ

កសិករភាគច្រើនបានធ្វើការសំរិតសំរាំងពូជស្រូវរបស់ខ្លួន តាមវិធីផ្សេងៗ ដើម្បីទុកយកទៅដាំដុះក្នុងរដូវ ឬឆ្នាំក្រោយ ។ តែមួយភាគធំក្នុងចំណោមកសិករទាំងនោះ នៅតែជួបប្រទះបញ្ហាពូជលាយច្រើនដដែល នេះប្រហែលជាគេមិនបានធ្វើដោយការប្រុងប្រយ័ត្ន។

⊗ តើហេតុអ្វីបានជាគេត្រូវធ្វើការសំរិតសំរាំងពូជស្រូវ? ពីព្រោះ

- គ្រាប់ពូជសុទ្ធល្អ
  - វានឹងផ្តល់ផលខ្ពស់
  - វានិងលក់បានក្នុងតម្លៃថ្លៃ
  - វានឹងដុះលូតលាស់បានល្អ
  - អាចរក្សាទុកបានយូរ
  - វានឹងមិនបណ្តាលអោយអង្ករបាក់ច្រើននៅពេលកិន

៥ តើអ្នកធ្វើដូចម្តេចទើបដឹងថាដើមស្រូវខុសគ្នា ?

- អ្នកត្រូវមើលលក្ខណៈមួយចំនួនដូចខាងក្រោម
  - កំពិតខ្ពស់ និងទាប
  - ពណ៌ដើម ឬស្លឹក
  - បែកគុម្ពក្រញ៉ាំង ឬកញ្ចុំ
  - ចេញផ្កា មុនឬក្រោយ
  - ស្លឹកស្រូវតូច ឬធំខ្លីឬវែង
  - គ្រាប់ស្រូវតូចធំ ខ្លី ឬវែង
  - ពណ៌នៃគ្រាប់ស្រូវ
  - តើចុងគ្រាប់ស្រូវមានអុចពណ៌ខ្មៅ ឬពណ៌ស្វាយឬទេ
  - តើមានកន្ទុយ ឬអត់កន្ទុយ
  - កួរស្រូវបែកក្រញ៉ាំង ឬកញ្ចុំ
  - ទំហំស្លឹកអបកួរស្រូវ
- អ្នកត្រូវច្រូតកាត់ស្រូវក្នុងផ្លែកបន្សុទ្ធពូជនោះ បោកបែន និងរក្សាទុកដាក់ដោយឡែកពីគេ និងដោយប្រយ័ត្នប្រយែងជាទីបំផុត ។

# លក្ខណៈខុសគ្នារវាងដើមស្រូវ :

## ក. កំពស់ដើមស្រូវ :



## ខ. ពេលវេលានៃការចេញកួរ :



គ. ស្លឹក ដើម និងពណ៌គ្រាប់ :



ឃ. មុំនៃស្លឹក :



ង. ដំណាកកួរ :



ច. ប្រភេទកួរស្រូវ :



ឆ. មុំនៃស្លឹកអមកួរ



ជ. ទំហំគ្រាប់ស្រូវ



ឈ. វត្តមាន ឬអវត្តមាននៃការដុះកន្ទុយ



៨ **តើយើងគួរធ្វើការសំរិតសំរាំងពូជដូចម្តេចទើបងាយស្រួល ហើយនិងបានល្អ ?**

<u>ឧបមាថា</u> : អ្នកមានស្រែពីរកន្លែង មួយកន្លែងនៅក្បែរផ្ទះ ដែលមានទំហំ ២០ អារ និងមួយកន្លែងទៀតឆ្ងាយពីផ្ទះដែល មានទំហំ ៨០ អារ ។ ស្រែទាំងពីរនេះធ្វើពូជតែមួយដូចគ្នា ហើយអ្នកត្រូវការគ្រាប់ពូជសំរាប់ស្រែទាំងពីរចំនួន ១០០ គ.ក

<u>លំដាប់នៃការអនុវត្តន៍</u> : អ្នកត្រូវជ្រើសរើសផ្នែកណានៃស្រូវ ដុះស្មើគ្នា និងល្អជាងគេ ត្រូវប៉ាន់ទំហំប៉ុន្មានដែលអាចទទួល បានផលយ៉ាងតិច ១២០ គីឡូក្រាម ។ <u>ឧទាហរណ៍</u> : មួយ ហិកតាបានផលជាមធ្យម ២ តោន ឬ ១០០ អារ អោយ ផល ២០០០ គីឡូក្រាម នោះយើងអាចត្រូវការផ្ទៃដី ៦ អារ ។



ជ្រើសរើសផ្ទៃដីធ្វើ សំរិតសំរាំងពូជ

កាត់ពូជលាយនៅ ៣ ដំណាក់ កាល បែកគុម្ព ចេញផ្កា ស្រូវទុំ



ច្រូតកាត់អោយបានមុនគេ



បោកបែនដោយឡែក



ហាលដោយឡែក



ច្រកទុកបាវដោយឡែក

⊛ <u>ឆ្នាំទីពីរ</u> : អ្នកត្រូវជ្រើសរើសកន្លែងសំរាប់ការធ្វើសិរិតសំរាំងពូជនៅឆ្នាំបន្តទៀតដោយ :



⊛ ការធ្វើជ្រើសរើស យកកូនស្រែដែលនៅជិតផ្ទះពីព្រោះងាយស្រួលក្នុងការថែទាំ។

⊛ ដីស្រែត្រូវមានជីវជាតិ រាបស្មើនិងងាយស្រួលក្នុងការបញ្ចេញបញ្ចូលទឹក ។

⊛ ធ្វើការកំណត់នូវទំហំកូនស្រែសំរាប់សិរិតសំរាំងពូជដោយ៖ បើផលនៅស្រែរបស់អ្នកបាន ២ ២ តោន នោះបានន័យថាក្នុងមួយអារ (១០ម៉ែត្រ x ១០ម៉ែត្រ) គឺបានផល ២០ គីឡូក្រាម ។ ដូចនេះបើអោយបាន ១០០ គីឡូក្រាម អ្នកត្រូវការផ្ទៃដី ៥ អារ ។ ប៉ុន្តែអ្នកត្រូវកំណត់យកផ្ទៃដី ៦អារ ព្រោះវាអាចបាត់បង់ដោយមូលហេតុផ្សេងៗ ។

⊛ ធ្វើការកំណត់ចំនួនពូជស្រូវប៉ុន្មានគីឡូសំរាប់ផ្ទៃដី ៦ អារ ដោយ : អ្នកដឹងថាក្នុងមួយហិកតាអ្នកប្រើពូជ ១០០ គីឡូក្រាម ហើយក្នុងមួយហិកតា ស្មើ ១០០ អារ ដូច

នេះក្នុងមួយអារ អ្នកត្រូវការគ្រាប់ពូជមួយគីឡូក្រាម ។ ដោយយើងមានដី ៦ អារ នោះយើងត្រូវការគ្រាប់ពូជ ៦ គីឡូក្រាម ។

- **<u>ចូរអ្នកធ្វើ</u>** :

- យកពូជ ៦ គីឡូក្រាម ពីពូជ ១០០ គីឡូក្រាម ដែលបាន ស៊រិតសំរាំងនៅឆ្នាំទីមួយ មកសាបដោយឡែកដោយ ៖

- ធ្វើថ្នាល អោយបានស្អាត និងស្មើល្អ ។
- លើកកូនភ្លឺព័ទ្ធជុំវិញ ។



- ភ្ជួររាស់និងពង្រាបដី៦ អារ នោះអោយបានរាបស្មើកំចាត់ស្មៅអោយបានស្អាតល្អ ។ គ្មានដុះមួរ ឬសារ ។ល។



- ចូរកុំទុកសំណាប អោយចាស់ជ្រុលពេក ។
- ការកាត់ពូជលាយគឺត្រូវធ្វើដូចកាលឆ្នាំទីមួយ ។
- ការច្រូតកាត់បោកបែន ហាលសំអាត និងទុកដាក់គឺត្រូវធ្វើដូចកាលឆ្នាំទីមួយដែរ ។

- <u>ឆ្នាំទីបី និងឆ្នាំបន្តបន្ទាប់</u> :

ចូរអ្នកធ្វើដូចកាលឆ្នាំទីពីរ ទាំងនៅលើស្រែកសិករសំរាប់សរិតសំរាំងពូជ ៥ ហិកតា និងស្រែដែលនៅសល់ ។

- បើអ្នកត្រូវការសរិតសំរាំងពូជស្រូវពីរ ឬផ្សេងៗគ្នានៅពេលតែមួយ ចូរអ្នកធ្វើតាមរបៀបដូចគ្នា ប៉ុន្តែត្រូវធ្វើនៅកន្លែងឆ្ងាយពីគ្នាបន្តិច ហើយការប្រមូលផល និងទុកដាក់ត្រូវធ្វើដោយឡែកពីគ្នា ។

<u>គួរចងចាំ</u> : គេធ្វើការសរិតសំរាំងពូជណាដែលមានផលខ្ពស់ គុណភាព អង្ករល្អ មានទីផ្សារ ។

* រៀបចំឯកសារ និង បោះពុម្ពផ្សាយដោយ :

គណៈកម្មការផលិតកម្មដំណាំស្រូវខេត្តតំបន់ពាយ៍ព្យ

១- លោក ហួត សុធី ប្រធាន

២- លោក ខាត់ ប៊ូរិន អនុប្រធាន

៣- លោក ហ៊ុយ ជេន លេខាធិការ

៤- លោក ចង សុក្ខាត ទីប្រឹក្សា

៥- លោក ទៀវ ប៊ុំជុន សមាជិក

៦- លោក ស៊ាង ឡៀហេង សមាជិក (អ្នកគូររូប)

៧- លោក សូ សារិន សមាជិក

៨- លោក ពុត លឿម សមាជិក

៩- លោក ផាង ស៊ីវុធ សមាជិក

១០- លោក ឡាយ វិសិដ្ឋ សមាជិក

១១- លោក សាន គីមសួរ សមាជិក

១២- លោក មុត វ៉ាន់ឌី សមាជិក

១៣- លោក អ៊ុក មករា នាយកដ្ឋានក្សេត្រសាស្ត្រ

* កែសំរួលដោយ

- នាយកដ្ឋានក្សេត្រសាស្ត្រ
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ខេត្តតំបន់ពាយ៍ព្យ

* ឧបត្ថម្ភថវិកាដោយ អង្គការឃែរេរ ( UNDP / UNOPS / CARERE )

បោះពុម្ពលើកទី២
ជាភាសាខ្មែរចំនួន
១៣១៣ច្បាប់ ១៩៩៨

## បណ្ណាល័យសាស្ត្រ

+ ផលិតកម្មគ្រាប់ពូជ (IRRI) ។

ឧបត្ថម្ភដោយឧបាសក ហៃ ប៉ើ

បោះពុម្ពលើកទី ២

ចំនួន ១៣១៣ ក្បាល

១៩៩៨